# ជំនឿលើពិធីឱ្យធម៌ (រៀបសូត្រ)

ជំនឿលើពិធីឱ្យធម៌ដល់មនុស្សជិតស្លាប់ ក្នុងសង្គមខ្មែរតាមជនបទនៅមាននៅឡើយ ពិសេសតំបន់ដែលមានកាន់ទំនៀមទំលាប់ច្រើន ដូចជាព្រៃវែង កំពង់ចាម បាត់ដំបង និងសៀមរាបជាដើម។ ពិធីនេះ ជាទំនៀមបែបព្រហ្មញ្ញសាសនាមួយ ដែលសង្កត់ធ្ងន់ទៅលើជំនឿនៃព្រលឹងរបស់មនុស្ស។ ប៉ុន្តែ ជំនឿនេះក៏បានក្លាយមកបែបពុទ្ធសាសនា ឬសំយោគក្នុងពុទ្ធសាសនា ដោយមានការនិមន្តព្រះសង្ឃមកសូត្រព្រះធម៌ចន្ទសុកគីរីសូត្រដែរ។ ជាធម្មតា គេធ្វើពិធីនេះ ព្រោះគេជឿថា អ្នកជំងឺគឺចៀសមិនផុតពីការស្លាប់។

**តើគេជឿរបៀបដូចម្តេច?**

អត្ថបទនេះ ខ្ញុំសុំលើកយកជំនឿរបស់មនុស្សក្នុងតំបន់ខាងក្រោមខេត្តសៀមរាបមកបង្ហាញត្រួសៗ។ អ្នកស្រុកខាងក្រោម (ចាប់ពីជាយទីរួមខេត្តសៀមរាបរហូតដល់មាត់បឹងទន្លេសាប) តែងជឿលើព្រលឹងរបស់មនុស្សដែលមានចំនួន១៩។ ក្នុងករណីបើមានមនុស្សឈឺរហូតដល់ព្យាបាលលែងជា ឬក៏អស់សង្ឃឹមក្នុងការព្យាបាល សមាជិកគ្រួសារតែងអញ្ជើញអាចារ្យយោគី (អាចារ្យធំ ឬមេអាចារ្យ) និងអាចារ្យក្មុកទាំង៤ (ពេលខ្លះមកតែម្នាក់)[១] មករៀបចំពិធីឱ្យធម៌ ឬពាក្យក្នុងតំបន់នោះ ហៅថា "**រៀបសូត្រ**"។ អាចារ្យយោគី (រូបលេខ១) គឺជាអាចារ្យធំដែលមានចំណេះ និងញាណពិសេសអាចប្រមើរមើលតាមរយៈការធ្វើសមាធិនាពេលរាត្រី ឬពាក់កណ្តាលយប់។ នៅពេលអាចារ្យយោគីធ្វើសមាធិរួចហើយ អាចារ្យយោគីនឹងប្រាប់ទៅសាច់ញាតិអ្នកជំងឺថា តើអ្នកជំងឺអាចជាឡើងវិញ ឬយ៉ាងណា? ក្នុងករណីខ្លះ អាចារ្យយោគីប្រាប់ថា ព្រលឹងអ្នកជំងឺជាប់នៅកន្លែងណាមួយ ត្រូវធ្វើពិធីហៅ មកវិញ អ្នកជំងឺនឹងបានជាសះស្បើយឡើងវិញ។[២] ក្នុងករណីមួយទៀត

---

[១] ជាធម្មតា សម្រាប់ពិធីបុណ្យ និងបូជាសព មានអាចារ្យចំនួន៥នាក់ គឺអាចារ្យយោគី១ និងអាចារ្យក្មុក៤។ អាចារ្យយោគីជាអាចារ្យធំ ឬមេគេ ដែលមានតួនាទីរៀបចំគ្រប់កិច្ចការ និងជាអ្នកនាំផ្លូវព្រលឹងរបស់សព។ ក្នុងពេលហែ អាចារ្យយោគីជាអ្នកសូត្រធម៌ឱ្យផ្លូវដល់ព្រលឹងសព និងក្នុងពិធីឱ្យភ្លើង ហើយអាចារ្យក្មុកទាំង៤និងធ្វើត្រាប់តាម រួចឆ្លើយសំនួនដែលអាចារ្យយោគីសួរចំនួន៣ដង ក្រោយដើរជុំវិញ ។(ដុតសព) ទើបបោះគុបភ្លើងទាំង៥ចូលទៅសព (ប្រសរ្វ ឬឧត្តពព័ត៌)

[២] ករណីនេះ យើងឃើញមានភាពជាក់ស្តែងចំពោះលោកតាម្នាក់ឈ្មោះ លោកតា វ៉ន អាយុជាង៧០ឆ្នាំ ជាអាចារ្យពេលារៀបចំមង្គលការ និងឡើងផ្ទះនៅភូមិស្ពានជ្រាវ សង្កាត់សៀមរាប បានឈឺធ្ងន់ ហើយបានរៀបចំពិធីឱ្យធម៌រហូតបានជាស្បះស្បើយមកវិញក្រោយពីការប្រមើរមើល និងធ្វើពិធីឱ្យធម៌នេះរួច។

អត្ថបទដោយ៖សុខ កែវ សុវណ្ណារ៉ា

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

ភាគច្រើនអាចារ្យយោគីតែងប្រមើរមើលឃើញថា ព្រលឹងរបស់អ្នកជំងឺ (ពិសេសព្រលឹងធំ) បានចាកចេញពីពងកាយរបស់អ្នកជំងឺហើយ គឺមានតែរង់ចាំដល់វេលាអ្នកជំងឺផុតដង្ហើមតែប៉ុណ្ណោះ។ ដូចនេះ គោលបំណងនៃការរៀបសូត្រនេះ គឺមានគោលដៅពីរសំខាន់ដែលប្រជាជនខ្មែរ តែងមានជំនឿ៖ ទី១ គឺអាចជួយឱ្យអ្នកជំងឺអាចជាសះស្បើយ។ ទី២ គឺជាការផ្តល់ធម៌ដល់អ្នកជំងឺមុននឹងស្លាប់ ដោយឱ្យព្រលឹងនោះនាំយកព្រះធម៌ទៅតាមផ្លូវនាំទៅដល់ព្រះពុទ្ធ (សក្យមុនីចេតិយ)។

### ពេលវេលានៃពិធី

ពិធីឱ្យធម៌នេះមិនកំណត់ពេលវេលាទេ គឺចាប់ផ្តើមតាំងពីដំបូងរហូតដល់អ្នកជំងឺជា ឬក៏ស្លាប់។ ក្នុងរយៈពេលនោះ រៀងរាល់ល្ងាច គេតែងនិមន្តព្រះសង្ឃមកសូត្រព្រះធម៌ (រូបលេខ២) រួចហើយវេលាយប់ អាចារ្យយោគី និងក្មុកសូត្រធម៌ចន្ទសុកគីរីសូត្រ (ត្រាំងគីរីមានន្ទសូត្រ)បន្ត។ ពេលខ្លះគេធ្វើពិធីសង្ឃទាន ដើម្បីធ្វើឱ្យអ្នកជំងឺស្ងប់ចិត្ត និងអស់អាល័យ (ដោយសារតែព្រលឹងបានចាក់ចេញពីប្រាណអស់ហើយ គេគិតថាអ្នកជំងឺមានសភាពដូចមនុស្សរុក្ខជាតិ គឺមិនអាចទទួលទានបានអ្វីទាំងអស់ មិនអាចនិយាយ និងស្តាប់ឮអ្វីឡើយ)។ គោលបំណងសំខាន់ គឺការឱ្យធម៌ដល់អ្នកជំងឺជារៀងរាល់ល្ងាច។ ប្រសិនបើអ្នកជំងឺជាសះស្បើយ គេនឹងបញ្ចប់ពិធីនោះ។ ប៉ុន្តែប្រសិនបើអ្នកជំងឺស្លាប់ គេនឹងធ្វើពិធីបុណ្យសពបន្តទៀត។ អ្នកជំងឺខ្លះអាចមានរយៈពេល១ទៅ២សប្តាហ៍ ឬមិនកំណត់តាមតែការអស់បុណ្យរបស់អ្នកជំងឺ។

### ការរៀបចំ

គេតែងដាក់អ្នកជំងឺឱ្យដេកបែរក្បាលទៅទិសខាងត្បូង។ គេចងព្រះបត់នៅលើក្បាលដំណេក ហើយព្រះបត់នោះមានគំនូរ៣ថ្នាក់ គឺខាងលើមានរូបព្រះពុទ្ធដែលត្រាស់រួចហើយ ៤អង្គ និងព្រះសិរ្យមេត្រីយ ១អង្គ គង់មួយជួរ បន្ទាប់មក គឺគំនូររូបព្រះចេតិយ ហើយខាងក្រោមគេបង្ហាស់ គឺរូបព្រះផ្ចាញ់មារ។ គេចងក្រណាត់ស ជាពងចតុកោណកែងត្រង់ចំពីលើអ្នកជំងឺ។ អាចារ្យរៀបចំបាយសី និងគ្រឿងរណ្តាប់ផ្សេងៗនៅក្បែរក្បាលអ្នកជំងឺផ្នែកខាងឆ្វេង មានដូចជា ទៀន៥ ធូប៥ ផ្កា៥ លាជ៥ ត្រួយ៥ និងទៀន១គូ ធូប១គូ ផ្កា១គូ លាជ១គូ ត្រួយ១គូ (រូបលេខ៣)។ គេធ្វើបាយសី១គូ ស្លាធម៌១គូ កន្ទោងម្លូស្លាបារី១

អត្ថបទដោយ៖សុខ កែវ សុវណ្ណារ៉ា

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

ដាក់នៅលើពាន ទិសឥសាន្ត (រូបលេខ២)។ ចំណុចពិសេសនោះ គឺគេរៀបចំចង្កៀងប្រេងកាត់មួយដាក់ព្យួរនៅទិសឥសាន្ត (រូបលេខ៥) ដែលតំណាងឱ្យដង្ហើមរបស់អ្នកជំងឺ (គេជឿថា ប្រសិនបើចង្កៀងរលត់ អ្នកជំងឺនឹងអស់ដង្ហើមដែរ គេតែងមើលថែ ពិសេសគឺការថែមប្រេងជាប្រចាំ)។

ពេលរៀបចំគ្រឿងរណ្តាប់រួចហើយ អាចារ្យយោគី តែងហៅឱ្យញាតិសន្តានអ្នកជំងឺមកជុំគ្នា ដើម្បីសុំខមាលទោស និងសូត្រ៣ដង ដើម្បីសុំឱ្យអ្នកជំងឺជាសះស្បើយពោគាទាំងឡាយ។ អាចារ្យសូត្រឬពោល (ចំនួន៣ដង) ថា៖ "កូនចៅមានចិត្តសទ្ធារៀបចំ សូមបវរណា រៀបសូត្រក្នុងវេលាល្ងាចនេះ មានទៀន៥ ធូប៥ ផ្កា៥ លាជ៥ ត្រួយ៥ និងទៀន១គូ ធូប១គូ ផ្កា១គូ លាជ១គូ ត្រួយ១គូ ហើយមានកម្មពារវេពទាំងអម្បាលមាន សូមជួយរំដោះគ្រោះ ជំងឺពោគាព្យាធិទាំងប៉ុន្មាន ក៏សូមព្រះអង្គកុំប្រកាន់ សូមឱ្យអ្នកជំងឺបានជាសះស្បើយទៅហោង" (កូនចៅញាតិសន្តានសំពះគោរពអ្នកជំងឺ) (រូបលេខ៦) រួចហើយទើបនិមន្តព្រះអង្គមកសូត្រមន្ត។ ក្រោយព្រះសង្ឃឱ្យធម៌ចប់ អាចារ្យទាំងអស់នឹងសូត្រគ្រាំងគីរីមានន្ទ ជារឿងរាល់ល្ងាចឱ្យអ្នកជំងឺស្តាប់។

នេះជាជំនឿតូចមួយដែល យើងគួរយកមកសិក្សាបន្ថែម និងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅលើឫសគល់នៃទំនៀមមួយនេះ។

អត្ថបទដោយ៖សុខ កែវ សុវណ្ណារ៉ា



រូបលេខ២១៖ អាចារ្យឱ្យសាច់ញាតិជុំអ្នកជំងឺ



រូបលេខ២២៖ ព្រះសង្ឃសូត្រមន្តឱ្យអ្នកជំងឺ



រូបលេខ២៣៖ គ្រឿងរណ្តាប់ផ្សេងៗ និងព្រះបត់



រូបលេខ២៤៖ ស្លាធម៌ និងកន្ទង់បារីម្លូស្លា



រូបលេខ២៥៖ ចង្កៀងតំណាងឱ្យ
ដង្ហើមអ្នកជំងឺ



រូបលេខ២៦៖ ការសុំខមាលទោសពីអ្នកជំងឺ

អត្ថបទដោយ៖សុខ កែវ សុវណ្ណារ៉ា